**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**
**អគ្គលេខាធិការដ្ឋាន**
លេខ ០៤២ រ.បក ...អ.ជ.ប.គ.ញ.

ថ្ងៃសុក្រ ៨រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខែមីនា និងលើកទិសដៅការងារខែមេសា ឆ្នាំ២០២៦

(ថ្ងៃទី១ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦)

អនុវត្តតាមទិសដៅការងារដែលបានដាក់ចេញពីខែកុម្ភៈឆ្នាំ២០២៦កន្លងទៅ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន(អ.ជ.ប.គ.ញ.) ក្នុងនាមជាសេនាធិការឱ្យអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសម្របសម្រួល ប្រមូលផ្តុំដឹកនាំនិងអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រកបដោយការយកចិត្តទុកដាក់និងទទួលខុសត្រូវខ្ពស់។ ដោយទទួលបាននូវលទ្ធផល ដូចខាងក្រោម៖

## I. សភាពការណ៍គ្រឿងញៀន

ក្នុងខែមីនា ឆ្នាំ២០២៦នេះ បទល្មើសគ្រឿងញៀន ស្របតាមស្ថានភាពកំពុងតែវិវត្តប្រែប្រួលដ៏ស្មុគស្មាញនិងប្រកបដោយភាពគ្រោះថ្នាក់គួរឱ្យព្រួយបារម្ភ។ ដោយក្រុមឧក្រិដ្ឋជនគ្រឿងញៀនតែងតែបង្កើតយុទ្ធសាស្ត្រ កលល្បិចថ្មីៗក្នុងការធ្វើសកម្មភាពចរាចរ ដឹកជញ្ជូន ជួញដូរនិងលួចលាក់កែច្នៃគ្រឿងញៀន ក្នុងនោះបទល្មើសគ្រឿងញៀនធំៗចាប់ពី ១គីឡូក្រាមឡើង ត្រូវបានសមត្ថកិច្ចបង្ក្រាប រួមមានបទល្មើសកែច្នៃនូវសារធាតុញៀន ៣ករណី នៅរាជធានីភ្នំពេញ និងខេត្តស្វាយរៀង ចាប់យកគ្រឿងញៀន **៥៦គីឡូក្រាម** ឃាត់ខ្លួនជនសង្ស័យ ១៤នាក់។ បទល្មើសដឹកជញ្ជូន ជួញដូរគ្រឿងញៀនឆ្លងដែនតាមផ្លូវអាកាស(ពីកម្ពុជាទៅអូស្ត្រាលី) ១ករណី នៅរាជធានីភ្នំពេញ ចាប់យកគ្រឿងញៀន **១គីឡូក្រាម** ។ ដោយឡែកបទល្មើសរក្សាទុក ដឹកជញ្ជូន និងជួញដូរនូវគ្រឿងញៀនក្នុងផ្ទៃប្រទេស ១២ករណី នៅរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ ពោធិ៍សាត់ សៀមរាប និងខេត្តតាកែវ ចាប់យកគ្រឿងញៀន **១០៨គីឡូក្រាម** ឃាត់ខ្លួនជនសង្ស័យ ២៥នាក់។

**ការកត់សម្គាល់** ក្រៅពីស្ថានភាពនៃបទល្មើសគ្រឿងញៀនខាងលើ ក្នុងក្របខ័ណ្ឌនៃការអនុវត្តផែនការយុទ្ធសាស្ត្រ ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១ បានបង្ហាញឱ្យឃើញថា ការងារផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន បានធ្វើសកម្មភាពជាប្រចាំ ការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនបានអនុវត្តកាន់តែសកម្ម និងមានប្រសិទ្ធភាពជាងមុន ការអនុវត្តវិធានការរដ្ឋបាលនិងវិធានការច្បាប់នៅតាមគោលដៅក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋាន ដោយធ្វើកិច្ចសន្យាជានាមិនឱ្យមានការជួញដូរនិងប្រើប្រាស់គ្រឿងញៀនក្នុងទីតាំង៖



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ. មានទីតាំងនៅក្នុងបរិវេណទីស្តីការក្រសួងមហាផ្ទៃ, Phone : (855) 23 721 648, (855) 16 721 648, P.O.Box: 151
E-mail: info@nacd.gov.kh Website: www.nacd.gov.kh

អាជីវកម្មរបស់ខ្លួនបានជាច្រើនកន្លែង និងការពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយ ប្រទេសជាប់ព្រំដែន ប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍ តាមរយៈកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ការផ្លាស់ប្តូរព័ត៌មាន និងចែករំលែកបទពិសោធទៅវិញទៅមកជាបន្តបន្ទាប់ផងដែរ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. ការផ្សព្វផ្សាយអប់រំ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

ការងារផ្សព្វផ្សាយអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយ និងតាមសហគមន៍ ទទួលបានលទ្ធផលដូចខាងក្រោម៖

#### ១.១. ការងារផ្សព្វផ្សាយអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ

បានសម្របសម្រួល និងអនុវត្តសកម្មភាពការងារផ្សព្វផ្សាយអប់រំនៅតាមប្រព័ន្ធផ្សព្វផ្សាយ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- តាមរយៈគេហទំព័ររបស់អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. (www.nacd.gov.kh) មានការចូលអានចំនួន **១១០.៦៦៦ដង** (នៅខែកុម្ភៈ មានចំនួន ៤៣.១២២ដង) ច្រើនជាង ៦៧.៥៤៤ដង កើនឡើង **១៥៦,៦%**
- ផ្សព្វផ្សាយអប់រំតាមរយៈឃ្លីបវីដេអូខ្លីៗ តាមបណ្តាញទំនាក់ទំនងសង្គម Facebook Page និងកម្មវិធីទូរស័ព្ទដៃ NoDrug របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- សហការសម្របសម្រួលជាមួយស្ថានីយ៍ទូរទស្សន៍ វិទ្យុ និងបណ្តាញព័ត៌មាន ដើម្បីធ្វើការផ្សព្វផ្សាយអប់រំអំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន
- ជួបតំណាងក្រសួង ស្ថាប័ន ដៃគូ និងមហាជន ដើម្បីបង្កើនការចូលរួមផលិតមាតិកាសម្រាប់ផ្សព្វផ្សាយតាមប្រព័ន្ធទំនាក់ទំនងសង្គម
- អនុញ្ញាតឱ្យក្រុមសារព័ត៌មានរបស់ស្ថានីយ៍ទូរទស្សន៍ CNC ចូលជួបធ្វើបទសម្ភាសន៍ ក្រោមប្រធានបទ «នរណាខ្លះប្រព្រឹត្តនិងនៅពីក្រោយការជួញដូរ និងចែកចាយគ្រឿងញៀន» នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.
- ចូលរួមជាវាគ្មិនកិត្តិយសនៅក្នុងកម្មវិធីសន្ទនាមតិ «ជីវិតយើង សង្គមយើង» ក្រោមប្រធានបទ ស្តីពី«វឌ្ឍនភាពនៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន» នៅអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា
- បញ្ច្រាបសារអប់រំស្តីពីបញ្ហាគ្រឿងញៀន ទៅក្នុងកម្មវិធីរបស់ក្រុមហ៊ុនហង្សមាសវីដេអូ បទចំរៀងនិងតន្ត្រីទេសចរណ៍របស់ក្រុមហ៊ុនហ្គាឡាក់ស៊ីណាវ៉ាត្រា កម្មវិធីប្រដាល់ដែលរៀបចំដោយសហព័ន្ធកីឡាប្រដាល់គុនខ្មែរនៅតាមបណ្តាទូរទស្សន៍នានា ក្រុមហ៊ុនMSA និងក្រុមហ៊ុនប៊ីខេអិល
- ឆ្លើយតបចម្ងល់មហាជននៅក្នុងFacebook និងPage របស់នាយកដ្ឋាន និងប្រធាននាយកដ្ឋានផ្សព្វផ្សាយ អប់រំ និងទំនាក់ទំនងសាធារណៈ ពាក់ព័ន្ធការព្យាបាលគ្រឿងញៀន និងចម្ងល់ផ្សេងៗពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន ទទួលបានការគាំទ្រគួរកត់សម្គាល់។

#### ១.២. ការងារផ្សព្វផ្សាយអប់រំតាមសហគមន៍

បានសហការសម្របសម្រួល និងអនុវត្តសកម្មភាពការងារផ្សព្វផ្សាយអប់រំនៅតាមសហគមន៍ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ អប់រំ ស្តីពីផលប៉ះពាល់ដល់សុខភាពបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន បារីអេឡិចត្រូនិក និងជំរុញការទាញនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug ដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា នៅខេត្តមណ្ឌលគិរី និងខេត្តរតនគិរី៖

- ចូលរួមផ្សព្វផ្សាយ អប់រំ ស្ដីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងកម្មវិធីចុះពង្រឹងការទប់ស្កាត់បទល្មើសគ្រឿងញៀននៅមណ្ឌលអប់រំកែប្រែទី៤ នៅខេត្តពោធិ៍សាត់

- ចូលរួមជាវាគ្មិនក្នុងកម្មវិធីបង្កើនចំណេះដឹងទូទៅ ក្រោមប្រធានបទ «ការយល់ដឹងពីបញ្ហាគ្រឿងញៀន និងផលប៉ះពាល់នៃការប្រើប្រាស់បារីអេឡិចត្រូនិក ជូនដល់សិស្សានុសិស្សនៃសាលាប៊ែលធីអន្តរជាតិ នៅរាជធានីភ្នំពេញ

- ចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាលើកកម្ពស់ការងារផ្សព្វផ្សាយ អប់រំ ស្ដីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ជំរុញការទាញយកនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug និងច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនក្នុងវិស័យអន្តរសាសនា នៅខេត្តកំពង់ស្ពឺ

- សហការជាមួយសមាគមសិល្បករខ្មែររៀបចំផលិតវីដេអូអប់រំ ស្ដីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ជំរុញការទាញយកនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug នៅរាជធានីភ្នំពេញ

- សហការជាមួយក្រសួងទេសចរណ៍ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តក្រចេះ និងវិស័យឯកជន រៀបចំឱ្យមានសកម្មភាពផ្សព្វផ្សាយអប់រំ ស្ដីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ជំរុញការទាញយកនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug ក្នុងពិធីបុណ្យទន្លេលើកទី១០ នៅខេត្តក្រចេះ

- សហការជាមួយក្រុមការងារក្រសួងមហាផ្ទៃ ចូលរួមតាំងបង្ហាញពីសមិទ្ធផលកម្មវិធីទូរស័ព្ទដៃ NoDrug និងថ្នាលឌីជីថលប្រមូលទិន្នន័យអ្នកញៀនគ្រឿងញៀន ក្នុងកម្មវិធីតាំងពិព័រណ៍ក្នុងទិវាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើកទី៤ ក្រោមប្រធានបទ «នវានុវត្តន៍ដើម្បីវឌ្ឍនភាពជាតិ» នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ

- សម្របសម្រួលជាមួយគណៈកម្មាធិការសម្របសម្រួល ជំរុញ អនុវត្ត និងត្រួតពិនិត្យការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៃក្រសួងមហាផ្ទៃ ដើម្បីជំរុញឱ្យរាជធានី ខេត្ត រៀបចំសកម្មភាពផ្សព្វផ្សាយអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន និងកម្មវិធីទូរស័ព្ទដៃ NoDrug

- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានធ្វើការផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀនបានចំនួន **១៨.០៩៦លើក** (នៅខែកុម្ភៈ មានចំនួន ១៦.៤៤១លើក) ច្រើនជាង ១.៦៥៥លើក កើនឡើង **១០,១%** ដោយគ្របដណ្ដប់លើអ្នកមកទទួលយកសារ **១.០៧៧.៤០៩នាក់** ស្រី ៥៩៧.២១៤នាក់ (នៅខែកុម្ភៈ មានចំនួន ៩៤៥.៣២៧នាក់) ច្រើនជាង ១៣២.០៨២នាក់ កើនឡើង **១៤%**

- បំផុស ផ្សព្វផ្សាយ ជំរុញការទាញយកនិងប្រើប្រាស់នូវកម្មវិធីទូរស័ព្ទដៃ NoDrug រហូតមកដល់ពេលបច្ចុប្បន្ននេះមានចំនួន **៨៦.០១០នាក់** (នៅខែកុម្ភៈ មានចំនួន ៨៤.២៤១នាក់) ច្រើនជាង ១.៧៦៩នាក់ កើនឡើង **២,១%**។

## ២. ការពង្រឹងប្រសិទ្ធភាពការងារព្យាបាល ស្ដារនីតិសម្បទា និងសមាហរណកម្ម

អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល ស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានយកចិត្តទុកដាក់ពង្រឹងគុណភាពសេវាព្យាបាល ការស្ដារនីតិសម្បទា និងការធ្វើសមាហរណកម្ម នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ មជ្ឈមណ្ឌលព្យាបាលនិងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ និងឯកជន ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

### ២.១.ការកាត់បន្ថយគ្រោះថ្នាក់បណ្ដាលមកពីការប្រើប្រាស់គ្រឿងញៀន

សម្របសម្រួល និងអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់បណ្ដាលមកពីការប្រើប្រាស់គ្រឿងញៀន ទទួលបាននូវលទ្ធផលដូចខាងក្រោម៖

- ក្រសួងសុខាភិបាល បានបន្តផ្តល់សេវាព្យាបាលឱសថជំនួសដោយមេតាដូន ដល់អ្នកញៀនហេរ៉ូអ៊ីន បានចំនួន ៥០នាក់ ស្រី ៨នាក់ ដែលមានទីតាំងនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងមន្ទីរបង្អែកច្បារអំពៅ

- អង្គការដៃគូបានអនុវត្តកម្មវិធីផ្តល់សេវាម្ជុល-សឺរ៉ាំង ចំពោះអ្នកប្រើប្រាស់គ្រឿងញៀន ដើម្បីបង្ការទប់ស្កាត់ការឆ្លងមេរោគអេដស៍ និងជំងឺឆ្លងផ្សេងៗតាមឈាម បានចំនួន **៧៤០នាក់** ស្រី ១២៥នាក់ (នៅខែកុម្ភៈ មានចំនួន ៧៣០នាក់) ច្រើនជាង ១០នាក់ កើនឡើង **១,៣%**។

## ២.២. ការងារព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

សម្របសម្រួល និងពង្រឹងសមត្ថភាពការងារព្យាបាល ស្តារនីតិសម្បទា និងការធ្វើសមាហរណកម្ម ទទួលបាននូវលទ្ធផលដូចខាងក្រោម៖

- តាមរយៈការព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ក្រសួងសុខាភិបាលបានផ្តល់សេវាព្យាបាលដល់អ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន បានចំនួន ៣៥២នាក់ ស្រី ១២៨នាក់ រួមមានមន្ទីរពេទ្យបង្អែកចំនួន ២០៣នាក់ ស្រី ១១១នាក់ និងមណ្ឌលសុខភាពចំនួន ១៤៩នាក់ ស្រី ១៧នាក់

- ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាមមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរដ្ឋ និងឯកជន រួមមាន អ្នកចូលថ្មីចំនួន ១.២៧៤នាក់ ស្រី៧៩នាក់ (ខែកុម្ភៈ មានចំនួន ១.៧០៧នាក់) អ្នកធ្វើសមាហរណកម្មចំនួន ១.២២២នាក់ ស្រី ៦៧នាក់ (ខែកុម្ភៈ មានចំនួន១.៤៨១នាក់ ស្រី ៩៤នាក់) និងអ្នកកំពុងស្នាក់នៅចំនួន ៨.៨៣៨នាក់ ស្រី ៤៨៦នាក់ (ខែកុម្ភៈ មានចំនួន ៨.៧៨៥នាក់ ស្រី ៤៧៤នាក់)

- សហការសម្របសម្រួលក្នុងការចូលរួមសិក្ខាសាលាស្តីពីការបន្សាបគ្រឿងញៀន និងស្តារនិតីសម្បទាសម្រាប់បុគ្គលិកសុខាភិបាល នៅទីក្រុងបុមបៃ ប្រទេសឥណ្ឌា

- សហការសម្របសម្រួលជាមួយគណៈអភិបាលខេត្តស្វាយរៀង ដើម្បីចុះពិនិត្យទីតាំងសាងសង់មជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ នៅខេត្តស្វាយរៀង

- រៀបចំកិច្ចប្រជុំពិនិត្យពិភាក្សាក្នុងការរៀបចំទម្រង់ទិន្នន័យអ្នកញៀនគ្រឿងញៀនឱ្យមានលក្ខណៈស្តង់ដាជាមួយតំណាងក្រសួងសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទា នៅអគ្គលេខាធិការដ្ឋាននៃអ.ជ.ប.គ.ញ

- រៀបចំបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ថ្នាលឌីជីថលប្រមូលទិន្នន័យអ្នកញៀនគ្រឿងញៀនដល់មន្ត្រីបម្រើការងារនៅមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរដ្ឋ និងឯកជនចំនួន៤ នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

- កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលរៀបចំដោយក្រសួងមុខងារសាធារណៈ នៅសាលាភូមិន្ទរដ្ឋបាល

- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីនិយាមនីតិវិធីប្រតិបត្តិសម្រាប់មជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលរៀបចំដោយក្រសួងសុខាភិបាល នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ។៩

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

ដើម្បីពង្រឹងប្រសិទ្ធភាពការងារអនុវត្តច្បាប់ ឈានទៅបំផ្លាញបណ្តាញអង្គការចាត់តាំងឧក្រិដ្ឋជនគ្រឿងញៀន និងការទប់ស្កាត់ការចរាចរគ្រឿងញៀនគ្រប់ប្រភេទឆ្លងកាត់តំបន់ព្រំដែន បានបន្តសហការសម្របសម្រួលជាមួយស្ថាប័នអនុវត្តច្បាប់ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគីជាមួយអន្តរជាតិ តំបន់ អនុតំបន់ ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

### ៣.១. ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់

ក្នុងក្របខ័ណ្ឌនៃការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ បានសហការសម្របសម្រួលក្នុងការរៀបចំ ចូលរួមកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល និងកម្មវិធីនានា ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

- រៀបចំវគ្គបណ្តុះបណ្តាលជំនាញក្នុងការទប់ស្កាត់ បង្ក្រាបការចរាចរគ្រឿងញៀនខុសច្បាប់ និងសារធាតុគីមីគ្រោះថ្នាក់ផ្សេងៗ តាមប្រព័ន្ធកុំព្យូទ័រ(CBT) ដល់មន្ត្រីតាមនាយកដ្ឋាននិងមន្ទីរពិសោធន៍គ្រឿងញៀនចំណុះអគ្គលេខាធិការដ្ឋាននៃអ.ជ.ប.គ.ញ. នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.
- រៀបចំកិច្ចប្រជុំប្រកាសបិទកិច្ចប្រតិបត្តិការរួមមជ្ឈមណ្ឌលសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ(SMCC) ឆ្នាំ២០២៥ សម្រាប់បណ្តាប្រទេសជាសមាជិកទាំង៦ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ តាមប្រព័ន្ធអនឡាញ
- ចូលរួមប្រចាំការនៅមជ្ឈមណ្ឌលព័ត៌មាន និងសម្របសម្រួលអាស៊ីប៉ាស៊ីហ្វិក សម្រាប់ការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មគ្រឿងញៀន(APICC) នៃសាធារណរដ្ឋកូរ៉េ ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី២ ស្តីពីការវិភាគព័ត៌មានសម្ងាត់ពាក់ព័ន្ធបញ្ហាគ្រឿងញៀន ដែលរៀបចំដោយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម(UNODC) តាមប្រព័ន្ធអនឡាញ
- ចូលរួមកិច្ចប្រជុំជាមួយតំណាងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តព្រៃវែង ដើម្បីពន្លឿនការបើកដំណើរការការិយាល័យទំនាក់ទំនងព្រំដែន(BLO) នៅច្រកទ្វារព្រំដែនអន្តរជាតិកោះរការឱ្យអនុវត្តបានឆាប់រហ័ស នៅខេត្តព្រៃវែង
- ចូលរួមកិច្ចប្រជុំបណ្តាញត្រួតពិនិត្យគ្រឿងញៀនអាស៊ានលើកទី២០(ADMN) ដែលរៀបចំការិយាល័យកណ្តាលគ្រឿងញៀនសិង្ហបុរី(CNB) តាមប្រព័ន្ធអនឡាញ
- ទទួលការរាយការណ៍ពីបញ្ហាគ្រឿងញៀន តាមរយៈកម្មវិធីទូរស័ព្ទដៃ NoDrug ចំនួន **១.៣៣១ករណី** (នៅខែកុម្ភៈ មានចំនួន ២.៣៣៦ករណី) តិចជាង ១.០០៥ករណី ថយចុះ **៤៣%** ក្នុងនោះដោះស្រាយរួច ១.២៩៦ករណី និងកំពុងដោះស្រាយ ៣៥ករណី។

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

តាមរយៈកិច្ចប្រតិបត្តិការរបស់កម្លាំងអនុវត្តច្បាប់ក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀន ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- បង្ក្រាបបទល្មើសគ្រឿងញៀនសរុបចំនួន **៩៥៦ករណី**(នៅខែកុម្ភៈ មានចំនួន ៩២៨ករណី) ច្រើនជាង ២៨ករណី កើនឡើង **៣%**។ ឃាត់ខ្លួនជនសង្ស័យសរុបចំនួន **២.៤៥៧នាក់** ស្រី ១៥៨នាក់(នៅខែកុម្ភៈ មានចំនួន ២.២២៥នាក់) ច្រើនជាង ២៣២នាក់ កើនឡើង **១០,៤%** ក្នុងនោះ ជនជាតិខ្មែរ

២.៣០២នាក់(ស្រី ១៤៤នាក់) និងជនជាតិបរទេស ១៥៥នាក់(ស្រី ១៤នាក់) រួមមាន វៀតណាម ៥៣នាក់ (ស្រី ១២នាក់) មីយ៉ាន់ម៉ា ១នាក់ បង់ក្លាដេស ៤នាក់ ឥណ្ឌូនេស៊ី ២នាក់ ថៃ ៤នាក់ ឥណ្ឌា ២នាក់ ឡាវ ១នាក់ នេប៉ាល់ ១នាក់ ប៉ាគីស្ថាន ២នាក់ អង់គ្លេស ១នាក់ និងចិន ៨៤នាក់ (ស្រី ២នាក់) ក្នុងនោះចិនតៃវ៉ាន់ ៦នាក់

– **ចាប់យកគ្រឿងញៀន** ចំនួន **១៦៦គ.ក្រ ១៨០,១៦ក្រាម**(នៅខែកុម្ភៈ មានចំនួន ៦៩គ.ក្រ ២០២,០៤ក្រាម) ច្រើនជាង ៩៦គ.ក្រ ៩៧៨,១២ក្រាម កើនឡើង **១៤០%**

– ចាប់យកសារធាតុគីមីផ្សំនិងសារធាតុគីមីពាក់ព័ន្ធ ចំនួន **៣៣,០៨គីឡូក្រាម**

– ចាប់យកកញ្ឆាស្ងួត ចំនួន **២,១៨៦ក្រាម**

– **សម្ភារចាប់យក**ក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ដែលបានបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត រួមមាន រថយន្ត ១៩គ្រឿង ម៉ូតូ ២៦០គ្រឿង ទូរស័ព្ទ ១.២១២គ្រឿង ជញ្ជីង ១១៣គ្រឿង អាវុធខ្លី ១២ដើម អាវុធវែង ៨ដើម និងរូបិយវត្ថុជាតិ អន្តរជាតិ(៣.០២៥.០០០រៀល និង២.០០០បាត)

– **អនុវត្តដីកា** បានចំនួន ៨៣ដីកា ចាប់ខ្លួនជនសង្ស័យចំនួន ៧០នាក់

– **ក្នុងចំនួនករណីគ្រឿងញៀនខាងលើ៖**

- ករណីបង្ក្រាបដោយ**សមត្ថកិច្ចនគរបាលចំនួន ៨៥៣ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន ២.១៦៩នាក់ (ស្រី ១១៤នាក់)
- ករណីបង្ក្រាបដោយ**សមត្ថកិច្ចកងរាជអាវុធហត្ថចំនួន ១០៣ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន ២៨៨នាក់ (ស្រី ៤៤នាក់)

– **ការកត់សម្គាល់លើបទល្មើសគ្រឿងញៀន៖**

- ករណីធំៗ ចាប់ពី **១គីឡូក្រាម**ឡើង មាន **១៦ករណី** (ចោទពីបទសម្អាតប្រាក់**៤ ករណី**) ឃាត់ខ្លួនជនសង្ស័យបាន **៥៦នាក់(ស្រី ១០នាក់)** ក្នុងនោះ ខ្មែរ ២៨នាក់(ស្រី៥នាក់) វៀតណាម ៥នាក់ (ស្រី ១នាក់) ឡាវ ១នាក់ ស្រី មីយ៉ាន់ម៉ា ១នាក់ និងចិន ២១នាក់ (ស្រី ៣នាក់) ចាប់យកគ្រឿងញៀន **១៦៥គីឡូក្រាម ៦៥១,៨៥ក្រាម** សារធាតុគីមីផ្សំនិងសារធាតុគីមីពាក់ព័ន្ធ **៧៥៦គីឡូក្រាម** និងកញ្ឆាក្រៀម **៣គីឡូក្រាម ១៣៨,៨១ក្រាម**
- ករណីមធ្យម ចាប់ពី ១០០ក្រាមឡើង មាន ១១២ករណី ឃាត់ខ្លួនជនសង្ស័យ ៣៧៥នាក់
- ករណីតូចតាច ចាប់ពី ៩៩ក្រាមចុះក្រោម មាន ៨២៨ករណី ឃាត់ខ្លួនជនសង្ស័យ ២.០២៧នាក់។

### ៣.៣. ការអនុវត្តវិធានការរដ្ឋបាល

ការចាត់តាំងអនុវត្តវិធានការរដ្ឋបាលបានចំនួន **២៧៥លើក** ក្នុងនោះ ចុះអប់រំម្ចាស់ទីតាំងអាជីវកម្មបាន ១៤៦លើក រួមមាន **៤គោលដៅ** (ផ្ទះសំណាក់ ៣លើក ផ្ទះជួល ១៣១លើក បាបារាំង ៧លើក និងKTV ៥លើក) និងអញ្ជើញម្ចាស់ទីតាំងអាជីវកម្មមកប្រជុំបាន ១២៩លើក អ្នកចូលរួមចំនួន ៦.៣៧៨នាក់(ស្រី ៣.២៨៦នាក់)។ ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ចុះធ្វើតេស្តរហ័សរកសារធាតុញៀនលើក្រុមគោលដៅបានចំនួន **១០៩លើក** លើមុខសញ្ញាចំនួន **១.០៤៧នាក់(ស្រី ៣៣៤នាក់)** រកឃើញវិជ្ជមានសារធាតុញៀន **១០១នាក់** ត្រូវបានសមត្ថកិច្ចបញ្ជូនតាមនីតិវិធីច្បាប់ទៅទទួលយកសេវាបន្សាបនិងព្យាបាល។៚

### ៣.៤.ការងារមន្ទីរពិសោធន៍គ្រឿងញៀន

– បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងដែលសង្ស័យជាគ្រឿងញៀន ចំនួន **១.៥៧៤សំណាក** ស្មើនឹង **៦០៤ករណី** ក្នុងនោះ សំណាកវិជ្ជមាន ១.៥០១សំណាក ស្មើនឹង ៩៥,៣៦% និងសំណាកអវិជ្ជមាន ៧៣សំណាក ស្មើនឹង ៤,៦៤%

– បានផលិតតេស្តពណ៌សម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀនជំហានដំបូង ប្រភេទម៉ាគ្វីតេស្ត (Marquis test) បានចំនួន ២.០០០តេស្ត

– បានផ្តល់តេស្តពណ៌សម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀនជំហានដំបូង និងស្រោមសំបុត្ររក្សាវត្ថុតាង រួមមាន៖

- ប្រភេទម៉ាគ្វី ចំនួន ១.៣០០តេស្ត និងប្រភេទកេតាមីន ចំនួន ៥០០តេស្ត ជូនដល់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ខេត្តប៉ៃលិន កងរាជអាវុធហត្ថខេត្តព្រះសីហនុ និងស្នងការដ្ឋាននគរបាលខេត្តកណ្តាល
- ស្រោមសំបុត្ររក្សាទុកវត្ថុតាង ចំនួន ៧៥០សន្លឹក ជូនដល់សាលាដំបូងខេត្តកំពង់ឆ្នាំង ស្នងការដ្ឋាននគរបាលខេត្តកណ្តាល និងស្នងការដ្ឋាននគរបាលខេត្តប៉ៃលិន។

ជាមួយគ្នានេះ តាមរយៈនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានផ្តល់តេស្តរហ័សរកសារធាតុញៀនតាមទឹកមូត្រ មានដូចជា៖ប្រភេទមេតំហ្វេតាមីន ចំនួន ៣៧.២៤០តេស្ត និងប្រភេទអ៊ិចស្តាស៊ី ចំនួន ១២០តេស្ត ជូនដល់ក្រសួងការពារជាតិ រដ្ឋបាលខេត្តបាត់ដំបង ស្នងការដ្ឋាននគរបាលខេត្តកណ្តាល ខេត្តប៉ៃលិន កងរាជអាវុធហត្ថខេត្តកណ្តាល ខេត្តកំពង់ស្ពឺ កងរាជអាវុធហត្ថខេត្តព្រះសីហនុ និងក្រុមការងារចម្រុះសម្រាប់ពង្រឹងការគ្រប់គ្រងមណ្ឌលអប់រំកែប្រែនិងពន្ធនាគាររាជធានី ខេត្តនៃគណៈកម្មការទទួលបន្ទុកអនុវត្តវិធានការរដ្ឋបាល។

## ៤. ការត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំ

បានអនុវត្តសកម្មភាពការងារគ្រប់គ្រងត្រួតពិនិត្យសារធាតុញៀននិងសារធាតុគីមីផ្សំ ដើម្បីបង្ការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពនូវការលួចបង្វែរពីជំនួញស្របច្បាប់ យកទៅកែច្នៃគ្រឿងញៀនខុសច្បាប់ ទទួលបានលទ្ធផលដូចខាងក្រោម៖

– ជំរុញក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងសុខាភិបាល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឱ្យបន្តណែនាំដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស អំពីការគ្រប់គ្រងការប្រើប្រាស់សារធាតុគីមីផ្សំស្ថិតក្រោមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងគោលការណ៍ណែនាំ

– ជំរុញក្រសួង ស្ថាប័នជំនាញ បន្តចុះត្រួតពិនិត្យការប្រើប្រាស់សារធាតុគីមីផ្សំគ្រឿងញៀន នៅតាមបណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាស ឱ្យបានជាប្រចាំ

– រៀបចំកិច្ចប្រជុំពិភាក្សាជាមួយតំណាងវិទ្យាស្ថានស្តង់ដារកម្ពុជា នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រៀមចុះត្រួតពិនិត្យការប្រើប្រាស់ និងការរក្សាទុកនូវសារធាតុគីមីផ្សំជាប់បញ្ញត្តិនៅតាមបណ្តាក្រុមហ៊ុន រោងចក្រ ដើម្បីបង្ការ ទប់ស្កាត់ការលួចបង្វែរពីជំនួញស្របច្បាប់យកទៅលួចលាក់ផលិតគ្រឿងញៀនខុសច្បាប់ នៅអគ្គលេខាធិការដ្ឋាននៃអ.ជ.ប.គ.៣.៥

– ក្រសួង ស្ថាប័នជំនាញមានសមត្ថកិច្ចពាក់ព័ន្ធ បានផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាតដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស ក្នុងការនាំចូលនូវវត្ថុធាតុដើមផលិតឱសថ និងសារធាតុគីមីផ្សំ ដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន **៤.២៣៨តោន ៧០គ.ក្រ** (នៅខែកុម្ភៈ មានចំនួន ៨.៨៤០តោន ៥០២គ.ក្រ) តិចជាង ៤.៦០២តោន ៤៣២គ.ក្រ ថយចុះ **៥២%**។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

ដើម្បីពង្រឹង និងពង្រីកប្រសិទ្ធភាពក្នុងការសម្របសម្រួលអនុវត្តយន្តការនៃកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនក្នុងក្របខ័ណ្ឌទ្វេភាគីជាមួយបណ្តាប្រទេសជាប់ព្រំដែន ជាលទ្ធផលមានដូចខាងក្រោម៖

– បន្តពង្រឹងប្រសិទ្ធភាពការងារការិយាល័យទំនាក់ទំនងព្រំដែន(BLO) រវាងកម្ពុជា-ឡាវ និងកម្ពុជា-វៀតណាម ជាប់ជាប្រចាំ

– បន្តពង្រឹងយន្តការភូមិ ឃុំ សង្កាត់ សគ្មានគ្រឿងញៀន ជាមួយបណ្តាប្រទេសជាប់ព្រំដែន។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់និងដៃគូអភិវឌ្ឍន៍នានា

ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពក្នុងការអនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀងនានា និងសម្របសម្រួលកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ អន្តរជាតិ និងជាមួយការិយាល័យអង្គការ UNODC ជាលទ្ធផលមានដូចខាងក្រោម៖

– ចូលរួមកិច្ចប្រជុំលើកទី៦៩ នៃគណៈកម្មការគ្រឿងញៀន(CND) និងព្រឹត្តិការណ៍អម (Side Event) ក្រោមប្រធានបទ «គ្រួសាររឹងមាំ»(Strong Families) ដែលរៀបចំដោយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម(UNODC) តាមប្រព័ន្ធអនឡាញ

– ផ្តល់ធាតុចូលលើសេចក្តីព្រាងផែនការសកម្មភាព ដើម្បីអនុវត្តភាពជាដៃគូសន្ទនាអាស៊ាន-ចក្រភពអង់គ្លេសសម្រាប់ឆ្នាំ២០២៧-២០៣១ ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

ដើម្បីបន្តពង្រឹងប្រសិទ្ធភាព និងធ្វើជាសេនាធិការក្នុងការចាត់តាំងដឹកនាំ អនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាលក្ខណពហុវិស័យនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

– អនុវត្តបទបញ្ជាលេខ០១ បប របស់រាជរដ្ឋាភិបាល ស្តីពីការដាក់ចេញវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបានធ្វើតេស្តរហ័សរកសារធាតុញៀនក្នុងទឹកមូត្រ ចំពោះមន្ត្រីរាជការស៊ីវិល នគរបាលជាតិ យោធិន និងមន្ត្រីជាប់កិច្ចសន្យា មកដល់បច្ចុប្បន្ននេះ**ចំនួន ១៤៣.៥១៨នាក់** ក្នុងនោះរកឃើញវិជ្ជមានសារធាតុញៀនចំនួន ១១១នាក់ បណ្តេញចេញពីក្របខ័ណ្ឌចំនួន ១០៨នាក់ និងកំពុងតាមដាន ៣នាក់។ ដោយឡែកក្នុងខែមីនា ឆ្នាំ២០២៦នេះ មានចំនួន ៤.១១៩នាក់ បានធ្វើតេស្តរហ័សរកសារធាតុញៀនក្នុងទឹកមូត្រ រកឃើញវិជ្ជមានសារធាតុញៀនចំនួន ៥នាក់ បណ្តេញចេញពីក្របខ័ណ្ឌ

– ជំរុញការអនុវត្តបទបញ្ជាលេខ០២ បប របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា

– ជំរុញក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត បន្តអនុវត្តសេចក្តីណែនាំ ស្តីពីដំណើរការធ្វើតេស្តរហ័សរកសារធាតុញៀនក្នុងទឹកមូត្រ។

– ជំរុញការអនុវត្តផែនការសកម្មភាព ស្តីពីការចាត់តាំងអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១

– រៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផ្សព្វផ្សាយផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅសណ្ឋាគារស៊េរីដង់សុខាភ្នំពេញ

– កិច្ចប្រជុំត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផ្សព្វផ្សាយផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅទីស្តីការគណៈរដ្ឋមន្ត្រី

– ប្រជុំត្រួតពិនិត្យលើការងាររបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនប្រចាំខែកុម្ភៈ និងលើកទិសដៅការងារខែមីនាឆ្នាំ២០២៦ នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

– ធ្វើបទបង្ហាញចែករំលែកបទពិសោធន៍ការសិក្សា នៃវគ្គបណ្តុះបណ្តាលស្តីពីការប្រឆាំង ការជួញដូរគ្រឿងញៀនខុសច្បាប់នៅប្រទេសឥណ្ឌាកន្លងទៅ ដល់មន្ត្រីមកពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នៅរាជធានីភ្នំពេញ

– កិច្ចប្រជុំបូកសរុបលទ្ធផលការងារក្នុងត្រីមាសទី១ឆ្នាំ២០២៦ និងលើកទិសដៅការងារបន្ទាប់របស់គណៈកម្មការទទួលបន្ទុកអនុវត្តវិធានការរដ្ឋបាល នៃគណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅទីស្តីការក្រសួងមហាផ្ទៃ

– កិច្ចប្រជុំពិនិត្យ និងពិភាក្សាលើគម្រោងចំណាយសម្រាប់ការរៀបចំគម្រោងអង្កេត ដើម្បីកំណត់បន្ទាត់មូលដ្ឋាន និងចំណុចដៅសម្រាប់សូចនាកររងទី២ ស្តីពីការ«យល់ឃើញរបស់ប្រជាពលរដ្ឋលើបញ្ហាគ្រឿងញៀន» នៃសូចនាករសមិទ្ធកម្មគន្លឹះទី១៣ «បទល្មើសពាក់ព័ន្ធនឹងសន្តិសុខ សុវត្ថិភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ» នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

– ចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលរៀបចំដោយក្រសួងអធិការកិច្ច នៅខេត្តកំពង់ឆ្នាំង

– ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីរបាយការណ៍នៃការប៉ាន់ប្រមាណអំពីកុមារ និងក្មេងជំទង់អាយុក្រោម១៨ឆ្នាំដែលរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន និងឯកសារទស្សនទាន នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ.

– បញ្ជូនខ្លឹមសារនៃការបញ្ចូលសារធាតុគីមីផ្សំថ្មី សារធាតុញៀនថ្មី និងសារធាតុប៉ះពាល់ប្រព័ន្ធប្រសាទទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ជូនក្រសួងសុខាភិបាល

– បន្តពិនិត្យសម្រេច និងដំណើរការអនុវត្តឯកសារទស្សនទានស្តីពីការអង្កេតអំពីការយល់ឃើញរបស់ប្រជាពលរដ្ឋលើបញ្ហាគ្រឿងញៀន

– បន្តសហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ជំរុញឱ្យមានប្រសិទ្ធភាពការងារផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន និងការបង្ក្រាបបទល្មើសគ្រឿងញៀន នៅតាមបណ្តាភូមិសាស្ត្រស្មុគស្មាញ។

**ក្រៅពីលទ្ធផលសកម្មភាពការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខាងលើ អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. បានចាត់បញ្ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងមន្ត្រី**ចូលរួមដូចខាងក្រោម៖៩

– កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រោមអធិបតីភាព**ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី** តំណាងដ៏ខ្ពង់ខ្ពស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅទីស្តីការគណៈរដ្ឋមន្ត្រី

– កម្មវិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី១១៥ ឆ្នាំ២០២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និង**លោកជំទាវ កែ សួនសុភី ស សុខា** នៅទីស្តីការក្រសួងមហាផ្ទៃ

– កិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅទីស្តីការក្រសួងមហាផ្ទៃ

– កិច្ចប្រជុំប្រចាំខែមីនា ស្តីពីការសម្របសម្រួលការងារអន្តរអង្គភាពចំណុះក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ

– ពិធីប្រគល់សញ្ញាបត្រនិងវិញ្ញាបនបត្រជូនដល់និស្សិត សិស្សនិងសិក្ខាកាមនគរបាលជ័យលាភី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅបណ្ឌិត្យសភានគរបាលកម្ពុជា ខេត្តកណ្តាល

– កិច្ចប្រជុំអន្តរក្រសួងកម្រិតថ្នាក់ដឹកនាំ ដើម្បីពិនិត្យនិងពិភាក្សាសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២៥ នៃការការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និងកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល(២០២៧-២០២៩) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ប៊ិន ត្រឈៃ** រដ្ឋមន្ត្រីក្រសួងផែនការ នៅទីស្តីការក្រសួងផែនការ

– កិច្ចប្រជុំពិនិត្យ និងបូកសរុបលទ្ធផលការងារនៃការអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ(២០១៦-២០២៥) ប្រចាំឆ្នាំ២០២៥ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

– កិច្ចប្រជុំលើកដំបូងរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ចក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ

– សិក្ខាសាលាស្តីពី «បទដ្ឋានអន្តរជាតិ ច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម» ដែលរៀបចំដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នៅរាជធានីភ្នំពេញ

– កិច្ចប្រជុំពិភាក្សាអំពីតម្រូវការក្របខណ្ឌជំនាញបច្ចេកវិទ្យាព័ត៌មានវិទ្យា(IT) សម្រាប់អង្គភាពចំណុះក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ

– កិច្ចប្រជុំលេខាធិការដ្ឋានក្រុមការងារទទួលបន្ទុកធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងដំរឿនមន្ត្រីជាក់ស្តែង នៅតាមរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ

– វគ្គបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ប្រព័ន្ធធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងដំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័នចំណុះអង្គការនីតិប្រតិបត្តិ ដែលរៀបចំដោយក្រសួងមុខងារសាធារណៈ តាមប្រព័ន្ធអនឡាញ

– ក្នុងយុទ្ធនាការផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ និងលើកកម្ពស់លក្ខខណ្ឌការងារសម្រាប់កម្មករនិយោជិតវ័យក្មេងនៅតាមសហគ្រាស ដែលរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅខេត្តក្រចេះ

– កិច្ចប្រជុំពិនិត្យនិងពិភាក្សាលើការរៀបចំផែនការបណ្តុះបណ្តាលមន្ត្រីនគរបាលជាតិសម្រាប់ឆ្នាំ២០២៧ របស់ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ

– កិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំខែមករាឆ្នាំ២០២៦ និងកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើខ្លឹមសារបច្ចេកទេសលម្អិតលើសេចក្តីព្រាងរបាយការណ៍ តាមដាន និងត្រួតពិនិត្យប្រចាំឆ្នាំ២០២៥ នៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ នៅទីស្តីការគណៈរដ្ឋមន្ត្រី

– កិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាព ការរៀបចំសៀវភៅសទ្ទានុក្រមបច្ចេកសព្ទក្នុងវិស័យសន្តិសុខសង្គមនៃក្រសួងមហាផ្ទៃ តាមប្រព័ន្ធអនឡាញ

– កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែមីនា ដើម្បីពិភាក្សាលើ«លទ្ធផលនៃការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ក្នុងត្រីមាសទី១ ឆ្នាំ២០២៦» នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

– សិក្ខាសាលាផ្សព្វផ្សាយការទប់ស្កាត់ជំងឺអេដស៍ និងកាមរោគ នៅទីស្តីការក្រសួងមហាផ្ទៃ

– ក្នុងកម្មវិធី «បញ្ជ្រាបការយល់ដឹងស្តីពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ» ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅរាជធានីភ្នំពេញ។

## III. ទិសដៅការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខែមេសា ឆ្នាំ២០២៦

ដើម្បីបន្តអនុវត្តឱ្យមានប្រសិទ្ធភាពលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. បានដាក់ចេញនូវទិសដៅការងារសម្រាប់ខែមេសា ឆ្នាំ២០២៦ ដូចខាងក្រោម៖

### ១. ការផ្សព្វផ្សាយអប់រំ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

**១.១.** បន្តសហការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ពង្រឹងការងារផ្សព្វផ្សាយអប់រំ តាមរយៈវិទ្យុ ទូរទស្សន៍ ទូរស័ព្ទដៃ សិល្បៈភាពយន្ត លើស្លាកសញ្ញាផលិតផលក្នុងស្រុក និងតាមរយៈប្រព័ន្ធទំនាក់ទំនងសង្គមផ្សេងទៀត។

**១.២.** បន្តសម្របសម្រួលនិងជំរុញក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ផលិតមាតិកាពាក់ព័ន្ធការផ្សព្វផ្សាយអប់រំអំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន។

**១.៣.** បន្តសហការនិងជំរុញរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជំរុញការទាញយក និងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug។

**១.៤.** បន្តពង្រឹងការបញ្ជ្រាបខ្លឹមសារអប់រំអំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀនតាមរយៈសកម្មភាពផ្សេងៗរបស់ដៃគូ។

**១.៥.** បន្តសហការនិងសម្របសម្រួលដើម្បីត្រៀមរៀបចំចុះអនុស្សរណៈនៃការយោគយល់រវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សហព័ន្ធកីឡាបាល់ទាត់ និងសហភាពសហព័ន្ធយុវជនកម្ពុជា។

**១.៦.** បន្តចលនា កៀរគរឱ្យមានការចូលរួមផុលផុសនិងគាំទ្រពីគ្រប់មជ្ឈដ្ឋានសង្គមលើការងារផ្សព្វផ្សាយអប់រំ ស្តីពីបញ្ហាគ្រឿងញៀន។

**១.៧.** បន្តសហការជាមួយបណ្តាញគ្រីស្ទបរិស័ទនៃក្រុមប្រឹក្សាបណ្តាញព្រះវិហារគ្រីស្ទបរិស័ទកម្ពុជា ដើម្បីអនុវត្តកម្មវិធីគ្រួសាររឹងមាំ( Strong Family )។៖

**១.៨.** ត្រៀមសហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ រៀបចំឱ្យមានសកម្មភាពផ្សព្វផ្សាយ អប់រំ ពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន និងជំរុញទាញយកនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug ក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្ត និងប្រជាពលរដ្ឋប្រើប្រាស់សេវារថយន្តក្រុងទៅលេងស្រុកកំណើតក្នុងឱកាសចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ។

**១.៩.** ត្រៀមសហការរៀបចំកម្មវិធីចុះហត្ថលេខាទទួលស្គាល់លើឯកសារគោលស្តីពីគ្រឿងញៀននៅសាកលវិទ្យាល័យការពារជាតិ។

## ២. ការពង្រឹងប្រសិទ្ធភាពការងារព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

**២.១.** បន្តសម្របសម្រួលជាមួយក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការផ្តល់ទិន្នន័យអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន។

**២.២.** បន្តជំរុញមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរដ្ឋ និងឯកជនឱ្យរៀបចំមាតិកាសម្រាប់ដាក់លើកម្មវិធីទូរស័ព្ទដៃ NoDrug។

**២.៣.** បន្តរៀបចំបណ្តុះបណ្តាលការប្រើប្រាស់ថ្នាលឌីជីថលប្រមូលទិន្នន័យអ្នកញៀនគ្រឿងញៀនដល់មន្ត្រីបម្រើការងារនៅតាមមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរដ្ឋ និងឯកជន។

**២.៤.** បន្តសម្របសម្រួលជាមួយតំណាងក្រសួងសន្តិសុខសាធារណៈនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ពាក់ព័ន្ធនឹងការស្នើសុំជំនួយសម្រាប់សាងសង់មជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ នៅខេត្តស្វាយរៀង។

**២.៥.** បន្តសហការនិងសម្របសម្រួលជាមួយគណៈអភិបាលខេត្តស្វាយរៀង ដើម្បីត្រៀមទទួលប្រតិភូវៀតណាម ចុះពិនិត្យទីតាំងសាងសង់មជ្ឈមណ្ឌលព្យាបាលនិង ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ នៅខេត្តស្វាយរៀង។

**២.៦.** ត្រៀមចុះពិនិត្យការអនុវត្តកម្មវិធីម្ទុល/សឺរ៉ាំងរបស់អង្គការមិត្តសំឡាញ់ និងអង្គការកសាង។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

**៣.១.** បន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ក្នុងការទប់ស្កាត់ជាអាទិភាពនូវការចោរចរគ្រឿងញៀនឆ្លងកាត់ព្រំដែន តាមផ្លូវគោក ទឹក អាកាស និងបញ្ញើប្រៃសណីយ៍ ពិសេសនៅតាមតំបន់ព្រំដែន។

**៣.២.** ត្រៀមចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីបច្ចេកទេសស៊ើបអង្កេតជាន់ខ្ពស់ ការគ្រប់គ្រងកន្លែងកើតហេតុ ការឃ្លាំងមើល និងការប្រគល់ទទួលដោយមានការឃ្លាំមើល នៅខេត្តសៀមរាប។

**៣.៣.** ត្រៀមផ្សព្វផ្សាយខ្លឹមសារសេចក្តីសម្រេច ស្តីពីការរៀបចំនឹងប្រព្រឹត្តទៅរបស់ការិយាល័យទំនាក់ទំនងព្រំដែន(BLO)។

**៣.៤. ការងារមន្ទីរពិសោធន៍គ្រឿងញៀន៖**

- បន្តពិនិត្យ និងធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងដែលសង្ស័យជាគ្រឿងញៀន ដើម្បីដោះស្រាយការកកស្ទះសំណុំរឿងរបស់សាលាដំបូងរាជធានី ខេត្ត
- បន្តផលិតឧបករណ៍តេស្តពណ៌សម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀនដំហានដំបូងប្រភេទម៉ាគីតេស្ត ( Marquis test) និងកេតាមីនតេស្ត ( Ketamine test ) ដើម្បីមានលទ្ធភាពផ្គត់ផ្គង់ឧបករណ៍ទាំងនេះ ដល់ស្ថាប័នអនុវត្តច្បាប់ សម្រាប់ប្រើប្រាស់ឱ្យបានគ្រប់គ្រាន់។

– ត្រៀមចូលរួមធ្វើតេស្តរកសារធាតុក្នុងទឹកមូត្រជូនដល់មន្ត្រីរាជការតាមក្រសួង ស្ថាប័ន អង្គភាពមួយចំនួន

– ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលអំពីវិធីការពារខ្លួនពីសារធាតុគីមីគ្រោះថ្នាក់ ដល់មន្ត្រីជំនាញចំណុះអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.។

## ៤. ការត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំ

**៤.១.** បន្តចុះជួបប្រជុំផ្សព្វផ្សាយ និងពង្រឹងយន្តការគ្រប់គ្រងត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំ ជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត និងអង្គភាពគយនិងរដ្ឋាករតាមច្រកទ្វារព្រំដែន។

**៤.២.** ត្រៀមសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ចុះត្រួតពិនិត្យការប្រើប្រាស់សារធាតុគីមីផ្សំ នៅតាមបណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាស ដើម្បីបង្ការទប់ស្កាត់ការលួចបង្វែរពីជំនួញស្របច្បាប់យកទៅផលិតគ្រឿងញៀនខុសច្បាប់។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

**៥.១.** បន្តពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ទ្វេភាគី ត្រីភាគី ពហុភាគី ជាមួយប្រទេសជាប់ព្រំដែន តាមរយៈការអនុវត្តតាមកំណត់ហេតុកិច្ចប្រជុំដែលបានឯកភាព ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៥.២.** បន្តសម្របសម្រួល និងសហការជាមួយប្រទេសជាប់ព្រំដែន ដើម្បីពង្រឹងយន្តការការិយាល័យទំនាក់ទំនងព្រំដែន(BLO)។

**៥.៣.** ត្រៀមរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទ្វេភាគី ត្រីភាគី កម្ពុជា-វៀតណាម-ឡាវ លើកទី១៩ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

**៦.១.** បន្តជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគីជាមួយបណ្តាប្រទេសក្នុងតំបន់ និងដៃគូ ដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**៦.២.** បន្តចូលរួមសហការសម្របសម្រួលអនុវត្តក្នុងភាពជាដៃគូ នៃកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី ជាពិសេសបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ។

**៦.៣.** បន្តសម្របសម្រួលអំពីវឌ្ឍនភាព នៃសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នា(MOU) ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនតាមលម្ហសមុទ្រ រវាងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាមួយកងកម្លាំងឆ្មាំសមុទ្រនៃសាធារណៈរដ្ឋកូរ៉េ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

**៧.១.** បន្តពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តបទបញ្ជាលេខ០១ បប របស់រាជរដ្ឋាភិបាល ស្តីពីការដាក់ចេញវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ៸

**៧.២.** បន្តពង្រឹងការអនុវត្តបទបញ្ជាលេខ០២ បប របស់រាជរដ្ឋាភិបាល ស្ដីពីការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា។

**៧.៣.** បន្តអនុវត្តផែនការ ស្ដីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១។

**៧.៤.** បន្តសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដើម្បីរៀបចំ និងកែសម្រួលសេចក្តីប្រកាសស្តីពីនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឱ្យលក់ដោយខុសច្បាប់។

**៧.៥.** ត្រៀមរៀបចំផ្សព្វផ្សាយពីតួនាទីភារកិច្ចរបស់ផ្នែកចំណុះការិយាល័យ តាមនាយកដ្ឋាន និងមន្ទីរពិសោធន៍ចំណុះអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.។

**៧.៦.** ត្រៀមចូលរួមអនុវត្តឯកសារទស្សនទានស្តីពីការអង្កេតអំពីការយល់ឃើញរបស់ប្រជាពលរដ្ឋលើបញ្ហាគ្រឿងញៀន។៸៚

**អគ្គលេខាធិការ**

ទាយឧត្តមសេនីយ៍ **មាស_វីរិទ្ធ**

**ចម្លងជូន៖**

- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.
  " ដើម្បីគោរពជូនជ្រាប "
- ឯកឧត្តមអនុប្រធាន និងសមាជិក អ.ជ.ប.គ.ញ.
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត
- អគ្គលេខាធិការរងនៃអ.ជ.ប.គ.ញ.
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី
- នាយកដ្ឋាននិងមន្ទីរពិសោធន៍នៃ អ.ជ.ប.គ.ញ.
  " ដើម្បីមុខការ "
- ឯកសារ កាលប្បវត្តិ